**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**
នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យ**
**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២ និងលើកទិសដៅការងារឆ្នាំ ២០២៣ របស់នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

## សេចក្តីផ្តើម

កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការដ្ឋានកែទម្រង់ស្នូលមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុសាធារណៈឲ្យដើរតួនាទីយ៉ាងសំខាន់ សំដៅចូលរួមជានាឲ្យកម្ពុជាមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង ។ ក្នុងន័យនេះ ក្រសួងអភិវឌ្ឍន៍ជនបទ នៅតែបន្តរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចឲ្យបានជោគជ័យនូវគោលនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ តាមរយៈការអនុវត្តគោលនយោបាយ "លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជននៅជនបទ ប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌" ដោយខិតខំធ្វើយ៉ាងណាជំរុញលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅជនបទឲ្យកាន់តែល្អប្រសើរឡើង ។ ក្រសួងអភិវឌ្ឍន៍ជនបទ ដែលមាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ ជាសេនាធិការហិរញ្ញវត្ថុ បាននិងកំពុងខិតខំអនុវត្តផែនការយុទ្ធសាស្រ្តថវិកាឲ្យបានសមស្រប ពង្រឹងការរៀបចំថវិកាប្រចាំឆ្នាំឲ្យបានគ្រប់ជ្រុងជ្រោយ និងសុក្រឹតភាព ដើម្បីបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ សំដៅរួមចំណែកលើកស្ទួយការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ ដែលជាធាតុចូលដ៏សំខាន់ចូលរួមគាំទ្រដល់ការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុថ្មី និងជាគ្រឹះដ៏រឹងមាំឆ្ពោះទៅអនុវត្តពេញលេញ ដែលនាំនូវការកែប្រែការគ្រប់គ្រងថវិកាទាំងស្រុងពោលគឺ ពីប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូល និងមធ្យោបាយ ទៅជាប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ និងការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឲ្យបានកាន់តែប្រសើរឡើង ដោយបែរឆ្ពោះទៅរកវិស័យអាទិភាព ។

ទន្ទឹមនឹងនេះ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ មានបេសកកម្មចម្បងក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងស័ក្តិសិទ្ធិភាព ដើម្បីធានានូវនិរន្តរភាពនៃដំណើរការរបស់ក្រសួងទាំងមូល ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ប្រភពហិរញ្ញវត្ថុ ជាពិសេសថវិការដ្ឋ ដោយអនុវត្តមុខងារសម្របសម្រួលជាមួយបណ្តាអង្គភាព-ស្ថាប័នពាក់ព័ន្ធ ក្នុងរៀបចំផែនការថវិកាប្រចាំឆ្នាំ ការការពារកញ្ចប់ថវិកា និងដំណើរការទូទាត់ចំណាយ របស់គ្រប់អង្គភាពដែលមាន

បេសកកម្មបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋនៅតំបន់ជនបទ នៃព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ នៅតែដើរតួនាទីយ៉ាងសំខាន់ និងមិនអាចខ្វះបាន ក្នុងការរួមចំណែកសម្រេចឲ្យបានជោគជ័យក្នុងកម្មវិធីអភិវឌ្ឍន៍ជនបទ ព្រមទាំងការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ **"ថវិកាសមិទ្ធកម្ម"** ស្របតាមអភិក្រម **"រៀនផង ធ្វើផង ឬ ឆ្លងស្ទឹង ស្ទាបថ្ម"** ។

## I- សមិទ្ធផលការងារសម្រេចបានក្នុងឆ្នាំ ២០២២

### ១. ការងារបុគ្គលិក

គិតត្រឹមដំណាច់ឆ្នាំ២០២២ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ មានមន្ត្រីសរុបចំនួន ៥៦នាក់ (កើនឡើង ០៣នាក់) ស្រី ៣២នាក់ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងមានអនុប្រធាននាយកដ្ឋានចំនួន ០៩រូប ជាជំនួយការ ។ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ មានការិយាល័យចំនួន ០៤ ជាសេនាធិការក្នុងការអនុវត្តមុខងាររបស់ខ្លួនឲ្យសម្រេចបានតាមបេសកម្ម និងគោលដៅ រួមមានការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ មានមន្ត្រីចំនួន ១២រូប ដឹកនាំដោយប្រធាន ០១រូប និងអនុប្រធាន ០៦រូប, ការិយាល័យគណនេយ្យ មានមន្ត្រីចំនួន ១១រូប ដឹកនាំដោយប្រធាន ០១រូប និងអនុប្រធាន ០៦រូប, ការិយាល័យហិរញ្ញកិច្ច មានមន្ត្រីចំនួន ១៥រូប ដឹកនាំដោយប្រធាន ០១រូប និងអនុប្រធាន ០៦រូប, ការិយាល័យសម្ភារ មានមន្ត្រីចំនួន ០៨រូប ដឹកនាំដោយប្រធាន ០១រូប និងអនុប្រធានចំនួន ០៥រូប ។

### ២. ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅក្នុងនាយកដ្ឋានផ្គង់ និងហិរញ្ញវត្ថុ មានភាពសាមគ្គីភាពផ្ទៃក្នុង និងមានកិច្ចសហការគ្នាបានល្អក្នុងការបំពេញការងារដោយយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងអនុវត្តតួនាទី ភារកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់ និងទទួលបានលទ្ធផលល្អជាទីមោទនភាពបំផុត ។ តាមរយៈការអនុវត្តវិធីសាស្ត្រលើកទឹកចិត្តមន្ត្រីឲ្យយកចិត្តទុកដាក់ និងខិតខំអនុវត្តការងារយ៉ាងសកម្មទៅតាមតួនាទី ភារកិច្ច ចំណេះដឹង ជំនាញ និងទេពកោសល្យរបស់មន្ត្រីម្នាក់ៗ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ សម្រេចបាននូវប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងមួយដ៏ល្អប្រសើរ ដែលជាហេតុធ្វើឲ្យដំណើរការនៃការអនុវត្តការងារកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល ។

ទន្ទឹមនឹងនេះ នាយកដ្ឋាននៅតែបន្តយកចិត្តទុកដាក់លើការអភិវឌ្ឍចំណេះដឹង សមត្ថភាព និងជំនាញដល់មន្ត្រីក្រោមឱវាទ តាមរយៈការបញ្ជូនមន្ត្រីឲ្យទៅចូលរួមវគ្គបណ្តុះបណ្តាល និងកម្មវិធីពង្រឹងសមត្ថភាពនានាដែលរៀបចំដោយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដូចខាងក្រោម ៖

- ការគ្រប់គ្រងសាច់ប្រាក់ និងការប្រើប្រាស់ប្រព័ន្ធសាច់ប្រាក់
- ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសូចនាករសមិទ្ធកម្មផែនការថវិកាកម្មវិធី
- ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធ SARMIS
- ការត្រៀមបម្រុងភ័ស្តុភារសម្រាប់ការងារជំនួយមនុស្សធម៌ថ្នាក់ជាតិ
- ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្ម ៩ខែដើមឆ្នាំ និងការណែនាំអំពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ

- បញ្ញាបការយល់ដឹងអំពីការដាក់ឲ្យអនុវត្តមុខងារថ្មីនៃប្រព័ន្ធ FMIS សម្រាប់មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ
- ជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,
- នីតិវិធីអនុវត្តការងារថ្មីលើចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប
- បែបបទ និងនីតិវិធីចំណាយលើការអន្តរគមន៍ជួសជុលបន្ទាន់ផ្លូវថ្នល់ និងផ្លូវជនបទ
- ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល
- គោលការណ៍ណែនាំ ស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង
- លទ្ធផលនៃការអនុវត្តថវិកាកម្មវិធី,
- បទពិសោធន៍ និងបញ្ហាប្រឈមនៃការអនុវត្តប្រព័ន្ធ FMIS
- គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្មសម្រាប់គ្រូបង្គោល ។

## ៣. ការងារផែនការថវិកា

នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ បានរៀបចំកញ្ចប់ថវិកាឆ្នាំ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទមានទិសដៅជាយុទ្ធសាស្រ្តកំណត់ចំណាយថវិកាសរុបចំនួន ៣២៨ ៨៩៥ លានរៀល ក្នុងនោះ ចំណាយចរន្តចំនួន ១៧៨ ៨៩៥ លានរៀល និងចំណាយមូលធនចំនួន ១៥០ ០០០ លានរៀល ។ ស្ថិតក្រោមកម្មវិធីទី ៤ ៖ ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ, នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុទទួលខុសត្រូវលើការអនុវត្តអនុកម្មវិធីចំនួន ០២ ដូចខាងក្រោម ៖

- អនុកម្មវិធីទី២ ៖ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាកម្មវិធី, ថវិកាចំនួន ៣៩១,១ លានរៀល អនុវត្តសម្រេចបាន ១០០% ទៅតាមចង្កោមសកម្មភាពចំនួន ០៤ ក្នុងនោះ ៖
  - ចង្កោមសកម្មភាពទី១ ៖ ផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី, បានរៀបចំបើកវគ្គសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី ចំនួន ០១វគ្គ នៅខេត្តសៀមរាប សិក្ខាកាមចូលរួមចំនួន ១៧៦នាក់, ថវិកាចំនួន ៧៦,៧ លានរៀល, អនុវត្តសម្រេចបាន ១០០%
  - ចង្កោមសកម្មភាពទី២ ៖ ប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី, ចុះបេសសកកម្មត្រួតពិនិត្យនីតិវិធីនៃការអនុវត្តចំណាយថវិកាកម្មវិធីនៅតាមមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ២៥ រាជធានី-ខេត្ត, ថវិកាចំនួន ១០៩,៩ លានរៀល, អនុវត្តសម្រេចបាន ១០០%
  - ចង្កោមសកម្មភាពទី៣ ៖ ពង្រឹងសមត្ថភាពគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ, បេសកកម្មចុះផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅតាមមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ២៥ រាជធានី-ខេត្ត, ថវិកាចំនួន ១២២,៩ លានរៀល, អនុវត្តសម្រេចបាន ១០០%
  - ចង្កោមសកម្មភាពទី៤ ៖ ពង្រឹងការប្រើប្រាស់ប្រព័ន្ធ FMIS, បើកវគ្គសិក្ខាសាលាស្តីពីការពង្រឹងការប្រើប្រាស់ប្រព័ន្ធ FMIS នៅខេត្តសៀមរាប, សិក្ខាកាមចូលរួមចំនួន ១៥៩នាក់, ថវិកាចំនួន ៨១,៦លានរៀល, អនុវត្តសម្រេចបាន ១០០% ។
- អនុកម្មវិធីទី៥ ៖ សេវាគាំទ្រគោលនយោបាយ, ថវិកាចំនួន ១៩ ៦១៨,៧ លានរៀល, អនុវត្តសម្រេចបាន ១០០% ទៅតាមចង្កោមសកម្មភាពចំនួន ០៥ ក្នុងនោះ ៖

- ចង្កោមសកម្មភាពទី១ ៖ សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងគោលនយោបាយ, បន្ទុកបុគ្គលិក និងបន្ទុកក្រៅបុគ្គលិក ប្រាក់បេសកកម្ម សេវាអនាម័យ ការថែទាំឧបករណ៍ ប្រេងឥន្ធនៈ និងប្រេងរំអិល សម្ភារការិយាល័យ សង្ហារិម អគ្គិសនីនិងទឹក ការថែទាំនិងជួសជុលបណ្តាញ មធ្យោបាយដឹកជញ្ជូន ឧបករណ៍បច្ចេកទេស ពន្ធនិងអាករ, ថវិកាចំនួន ១៨ ៤០៣,៤ លានរៀល, អនុវត្តសម្រេចបាន ៩៦,៤%
- ចង្កោមសកម្មភាពទី២ ៖ ផ្សព្វផ្សាយលទ្ធផលសន្និបាតប្រចាំឆ្នាំ, រៀបចំសន្និបាតបូកសរុបលទ្ធផលការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន ០១លើក នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ អ្នកចូលរួមចំនួន ៣៥០នាក់, ថវិកាចំនួន ៨៤,៣ លានរៀល, អនុវត្តសម្រេចបាន ១០០%
- ចង្កោមសកម្មភាពទី៣ ៖ ការជួសជុលថែទាំអគាររដ្ឋបាល, ថវិកាចំនួន ៦៣១ លានរៀល, អនុវត្តសម្រេចបាន ១០០%
- ចង្កោមសកម្មភាពទី៤ ៖ ការផ្គត់ផ្គង់សម្ភារបរិក្ខាបច្ចេកទេសមិនមែនព័ត៌មានវិទ្យា, ថវិកាចំនួន ១០០ លានរៀល, អនុវត្តសម្រេចបាន ១០០%
- ចង្កោមសកម្មភាពទី៥ ៖ ការផ្គត់ផ្គង់សម្ភារបរិក្ខាបច្ចេកទេសព័ត៌មានវិទ្យា, ថវិកាចំនួន ៤០០ លានរៀល, អនុវត្តសម្រេចបាន ១០០% ។

## ៤. ការចារទូទាត់ថវិកា

ក្រសួងអភិវឌ្ឍន៍ជនបទ (រដ្ឋបាលកណ្តាល) មានថវិកាអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ ចំនួន ២៨១ ៨០៧ លានរៀល, ចលនាឥណទានកើន (ជំពូក ២១) ចំនួន ៧០ ០០០ លានរៀល, ឥណទានថ្មីសរុបមានចំនួន ៣៥១ ៨០៧ លានរៀល, អនុវត្តសម្រេចបាន ៩៨,៩% ទៅតាមប្រភេទចំណាយដូចខាងក្រោម ៖

- **ចំណាយចរន្តរបស់រដ្ឋបាលកណ្តាល**

ច្បាប់ថវិកាឆ្នាំ ២០២២ បានកំណត់ចំណាយចរន្តរបស់ក្រសួងអភិវឌ្ឍន៍ជនបទ (រដ្ឋបាលកណ្តាល) ចំនួន ១៣១ ៨០៧ លានរៀល, អនុវត្តចំណាយបានចំនួន ៩៧,២% ទៅតាមជំពូកដូចខាងក្រោម ៖

- ជំពូក ៦០ ៖ ការទិញ គឺការទិញសម្ភារសម្រាប់ការងារថែទាំទាំងឡាយ ដែលអនុវត្តដោយស្ថាប័នរដ្ឋ ចំណាយលើសម្ភារផ្គត់ផ្គង់រដ្ឋបាល ស្បៀងអាហារ ការតុបតែង និងការប្រើប្រាស់ថាមពលអគ្គិសនី និងទឹក, ថវិកាចំនួន ៣ ២៤០ លានរៀល, អនុវត្តចំណាយបានចំនួន ៩៦,១%
- ជំពូក ៦១ ៖ សេវាខាងក្រៅ គឺចំណាយលើសេវាខាងក្រៅ ដូចជាការជួសជុលមធ្យោបាយដឹកជញ្ជូន ថ្លៃឈ្នួល និងបន្ទុក (អសង្ហារិម) សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស ការថែទាំ និងជួសជុល, ថវិកាចំនួន ១១២ ៨១៣ លានរៀល, អនុវត្តចំណាយបានចំនួន ៩៧,២%

- ជំពូក ៦៤ ៖ បន្ទុកបុគ្គលិក គឺចំណាយលើបន្ទុកបុគ្គលិកដូចជា បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់ឧបត្ថម្ភនិវត្តជន លាភការ រង្វាន់ផ្សេងៗ និងប្រាក់វិភាជន៍សង្គមសម្រាប់អំណាចសាធារណៈ បុគ្គលិកក្របខណ្ឌអចិន្ត្រៃយ៍ បុគ្គលិកមិនមែនក្របខណ្ឌ និងបុគ្គលិកអណ្តែតដែលមានទិដ្ឋាការពីរដ្ឋលេខាធិការមុខងារសាធារណៈ, ថវិកាចំនួន ១៥ ០៧៩ លានរៀល, អនុវត្តចំណាយបានចំនួន ៩៩,៨%
- ជំពូក ៦៣ ៖ ពន្ធ និងអាករ គឺចំណាយលើបន្ទុកពន្ធ និងអាករដូចជា លតាប័ត្រ និងបន្ទុកពន្ធប្រថាប់ត្រា, ថវិកាចំនួន ២៧២ លានរៀល, អនុវត្តចំណាយបាន ១០០%
- ជំពូក ៦៥ ៖ ឧបត្ថម្ភធន គឺចំណាយសម្រាប់ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌគោលដៅក្នុងទិសដៅនៃការផ្ទេរមុខងារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ថវិកាចំនួន ៤១០ លានរៀល, អនុវត្តចំណាយបានចំនួន ១០០%
- ជំពូក ៦២ ៖ អត្ថប្រយោជន៍សង្គម គឺចំណាយលើការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងអភិវឌ្ឍន៍ជនបទ, ថវិកាចំនួន ៤៥ លានរៀល, មិនបានអនុវត្តចំណាយ ។

- **ចំណាយមូលធន** (**គម្រោងវិនិយោគផ្ទាល់**)

គម្រោងវិនិយោគផ្ទាល់ (ថវិកាជំពូក ២១) ៖ គឺជាគម្រោងវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកសម្រាប់ការងារស្តាបនា ស្តារ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ លូ និងស្ពាន ។ ច្បាប់ថវិកាឆ្នាំ២០២២ ថវិកាជំពូក ២១ មានចំនួន ១៥០ ០០០ លានរៀល, ចលនាឥណទានកើត ៧០ ០០០ លានរៀល, ឥណទានថ្មីមានចំនួន ២២០ ០០០ លានរៀល, អនុវត្តចំណាយបានចំនួន ៩៩,៨% ។

## III- បញ្ហា និងការប្រឈម

បញ្ហា និងការប្រឈមចម្បងដែលនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ បានជួបប្រទះក្នុងការអនុវត្តការងារកន្លងមក មានដូចខាងក្រោម ៖

- ការមិនទាន់បញ្ចប់ទាំងស្រុងនៃជំងឺកូវីដ ១៩ ៖ ថ្វីត្បិតតែអត្រាឆ្លងនៃជំងឺកូវីដ ១៩ ស្ថិតក្នុងដំណាក់កាលដែលអាចគ្រប់គ្រងបាន ប៉ុន្តែការប្រយុទ្ធប្រឆាំងរបស់រាជរដ្ឋាភិបាលនៅតែបន្ត ជាពិសេសគឺយុទ្ធនាការចាក់វ៉ាក់សាំង ដែលជាហេតុធ្វើឲ្យថវិកាកញ្ចប់ថវិការបស់ក្រសួងនៅតែបន្តកាត់បន្ថយ ឬកើនឡើងក្នុងកម្រិតមួយទាប បើធៀបនឹងពិដានថវិកាមុនការផ្ទុះនៃជំងឺកូវីដ ១៩ ។
- ចំពោះការទូទាត់ចំណាយថវិកា ស្ថិតកក្នុងកម្រិតមួយដែលមានភាពប្រសើរឡើង បើប្រៀបធៀបនឹងបណ្តាឆ្នាំនៃការផ្ទុះជំងឺកូវីដ ១៩ ។ ទោះជាយ៉ាងនេះក្តី ការកសាងឯកសារទូទាត់ពីសំណាក់អ្នកទទួលការ ក៏នៅមានភាពយឺតយ៉ាងបណ្តាលមកពី កត្តាទឹកជំនន់ ដែលប៉ះពាល់យ៉ាងខ្លាំងដល់ដំណើរការនៅការដ្ឋានរបស់អ្នកទទួលការ ។

## IV- មេរៀន និងបទពិសោធន៍

- បើទោះបីជាជួបប្រទះបញ្ហា និងការប្រឈមយ៉ាងណាក្តី នាយកដ្ឋាននៅតែអាចអនុវត្តបានដោយជោគជ័យនូវ ផែនការថវិកាឆ្នាំ ២០២២ ដោយប្រកាន់យកគោលការណ៍អនុវត្តការងារតាមគន្លងថ្មី ក្នុងបរិបទកូវីដ ១៩

- ថវិកាឆ្នាំ ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានវិភាជន៍ឲ្យស្របទៅតាមសកម្មភាពជាអាទិភាពរបស់ក្រសួង ដែលរក្សាបាននូវ តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ក្នុងក្របខណ្ឌកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ
- ការបន្តពង្រឹង និងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ នៅតែជាយន្តការដ៏សំខាន់ដែលនាយកដ្ឋានបន្តប្រកាន់ខ្ជាប់ ដើម្បីការអនុវត្តការងារកាន់តែមានប្រសិទ្ធភាព
- បន្តការតាមដាន និងការត្បិតត្បៀតចំណាយចរន្ត ជាពិសេស បន្តការសន្សំសំចៃលើមុខសញ្ញាចំណាយ ការជួសជុលរថយន្ត ប្រេងឥន្ធនៈ អគ្គិសនី ទឹកស្អាត និងទូរស័ព្ទ ។

## V- **សេចក្តីសន្និដ្ឋាន**

នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ នៅតែដើរតួនាទីយ៉ាងសំខាន់ និងមិនអាចខ្វះបានក្នុងការរួមចំណែកសម្រេចឲ្យបាន គោលដៅអភិវឌ្ឍន៍របស់ក្រសួងអភិវឌ្ឍន៍ជនបទ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា ។ សមិទ្ធផល និងស្នាដៃខាងលើ បង្ហាញឲ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ ដែលបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានយ៉ាងល្អប្រសើរ ដោយអនុវត្តការងារប្រកបដោយភាពឆ្លើយតប តម្លាភាព ប្រសិទ្ធភាព គណនេយ្យភាព និងប្រសិទ្ធផល ។

សរុបមក នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ នៅតែមានសុទិដ្ឋិនិយមចំពោះលទ្ធផលដែលទទួលបាន ហើយជោគជ័យនេះអាចកើតឡើងបាន អាស្រ័យដោយមានការគាំទ្រទាំងសម្ភារ និងស្មារតីពីសំណាក់ **ឯកឧត្តមបណ្ឌិតសាចារ្យ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** ដែលធ្វើឲ្យនាយកដ្ឋានកាន់តែមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ឲ្យទទួលបានជោគជ័យ ។ ថវិកាឆ្នាំ ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅតែជាឧបករណ៍គោលនយោបាយដ៏សំខាន់សម្រាប់បន្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេស ដើម្បីបន្តគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្ពោះទៅសម្រេចឲ្យបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ឈានទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ដើម្បីធានាដល់ការអភិវឌ្ឍ វិបុលភាព សុខុមាលភាព និងសុខដុមនភាពរបស់ប្រជាជនកម្ពុជា ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ថ្ងៃសុក្រ ៩កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០២២
**ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**